# សលាកប័ត្រព័ត៌មានៈ អំពើហិង្សាប្រឆាំងនឹងស្ត្រីនៅក្នុងប្រទេសកម្ពុជា

**ទិដ្ឋភាពរួម ៖** អំពើហិង្សាផ្អែកលើយេនឌ័រគឺជាបញ្ហាមួយរីករាលដាលនៅក្នុងសង្គមកម្ពុជា។ អំពើហិង្សាមានច្រើនរូបភាពដែលប្រព្រឹត្តដោយបុគ្គលឯកជននិងស្ថាប័នផ្សេងៗគ្នា។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការប្រយុទ្ធប្រឆាំងនឹងការរើងអើងដោយធ្វើការជាមួយតួអង្គដទៃទៀត ក្នុងនោះរួមមានអង្គការសង្គមស៊ីវិលផងដែរ។ យ៉ាងណាក៏ដោយ នៅតែមានបញ្ហាជាច្រើនទៀតដែលត្រូវចាត់វិធានការបន្ថែម។ ហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវតែចាត់វិធានការសំខាន់ៗដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាប្រឆាំងនឹងស្ត្រីដើម្បីឆ្ពោះទៅរកការគោរពសិទ្ធិស្ត្រីឲ្យបានកាន់តែល្អប្រសើរនៅពេលអនាគត។

## សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះសង្ខេបនូវបញ្ហាសំខាន់ៗ ទាក់ទងទៅនឹងអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងប្រទេសកម្ពុជា។ ស្ត្រីកម្ពុជាទទួលរងអំពើហិង្សាជាច្រើនរូបភាពដែលវាជាការរាំងលទ្ធភាពរបស់ពួកគាត់ក្នុងការទាមទារសិទ្ធិដែលមានចែងនៅក្នុងច្បាប់ជាតិនិងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ បញ្ហាដែលរីករាលដាលជាច្រើននៃអំពើហិង្សាផ្អែកលើយេនឌ័រគឺជាអ្វីដែលស្ត្រីជាច្រើនប្រឈមនិងរាំងដល់សិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានយុត្តិធម៌។

## ស្ថានភាព

នាប៉ុន្មានឆ្នាំចុងក្រោយនេះ មានការអភិវឌ្ឍវិជ្ជមានមួយចំនួនក្នុងការប្រយុទ្ធប្រឆាំងអំពើហិង្សាកើតលើស្ត្រីនៅប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ។ ឧទាហរណ៍ ចំណុចគួរឱ្យកត់សម្គាល់រួមមាន:

- ក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍ព័ត៌មានអំពើហិង្សាលើស្ត្រី ឆ្នាំ២០១៧
- គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលរងជនគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឆ្នាំ២០១៦
- របាយការណ៍ស្តីពីការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (២០១៤-២០១៨)
- នារីរតនៈទី៤៖ ផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រីពីឆ្នាំ ២០១៤ ដល់ឆ្នាំ២០១៨

ទោះបីជាមានការអភិវឌ្ឍវិជ្ជមានមួយចំនួន ប៉ុន្តែចេនាសម្ព័ន្ធនិងទំនៀមទម្លាប់សង្គមនៅតែចាក់ដោតយ៉ាងជ្រៅក្នុងសង្គមកម្ពុជា។ ថ្វីបើការអប់រំអំពីច្បាប់ស្រីដែលជាក្រមសីលធម៌បែបប្រពៃណីដល់ស្ត្រីនៅមានតិចតួចនៅតាមសាលារៀនក៏ដោយ ច្បាប់ស្រីដែលជាក្រមសីលធម៌បែបប្រពៃណីសម្រាប់ស្ត្រីនៅតែមានឥទ្ធិពលក្នុងការកំណត់ឥរិយាបថស្ត្រីឲ្យក្លាយជាស្ត្រីគ្រប់លក្ខណ៍នៅក្នុងសង្គមខ្មែរនៅឡើយ។ បុរសនិងស្ត្រីត្រូវបានកំណត់តួនាទីយេនឌ័រយ៉ាងជាក់លាក់ អាស្រ័យ

ទៅតាមជំនឿ វប្បធម៌និងប្រពៃណីដែលបានចាក់ឬសហើយទាំងនេះបានបែងចែករវាងអំណាចក្នុងភាពជាបុរសនិងភាពទន់ខ្សោយក្នុងនាមជាស្ត្រី។ ដោយសារការកំណត់ដោយគ្មានហេតុផលថាស្ត្រីគឺជាមនុស្សដែលមានចិត្តសាស្ត្រទន់ខ្សោយតាំងពីធម្មជាតិ ស្ត្រីត្រូវបានគេរំពឹងថានឹងដើរតួនាទីជាអ្នកថែទាំ និងទទួលខុសត្រូវកិច្ចការងារផ្ទះ។

ទាំងនេះបានបង្ហាញថា តម្លៃសង្គមអាចធ្វើឲ្យកើតមានអំពីហិង្សាផ្អែកលើយេនឌ័រក្នុងដំណើរជីវិតទាំងនៅក្នុងផ្ទះ ក្នុងសហគមន៍និងនៅកន្លែងធ្វើការ ហើយនេះអាចកើតឡើងដោយសារតែសមាជិកគ្រួសារ មិត្តរួមការងារ និងមន្ត្រីសាធារណៈ។ ករណីធ្ងន់ធ្ងរមួយចំនួនពាក់ព័ន្ធអំពើហិង្សាផ្អែកលើយេនឌ័រគឺអាចប្រព្រឹត្តដោយបុគ្គលនៅក្នុងប្រព័ន្ធយុត្តិធម៌ផ្ទាល់ ហើយនេះបង្កនូវការព្រួយបារម្ភអំពីសមត្ថភាព និងប្រសិទ្ធិភាពរបស់ស្ថាប័នដែលមានភារកិច្ចក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។




ថ្វីបើរាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រដូចដែលបានរៀបរាប់ខាងលើក៏ដោយ បញ្ហាជាច្រើននៅតែកំពុងប៉ះពាល់ដល់ជីវិតស្ត្រីជាទូទៅ។ តាមការស្រាវជ្រាវថ្នាក់ជាតិអំពីសុខភាព និងបទពិសោធន៍ជីវិតរបស់ស្ត្រីដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនិងក្រសួងកិច្ចការនារីក្នុងឆ្នាំ២០១៥ បានបង្ហាញថា ២០ ភាគរយ នៃស្ត្រីកម្ពុជាធ្លាប់ទទួលរងហិង្សាលើរូបរាងកាយ និងផ្លូវភេទពីដៃគូរបស់ពួកគេ។ ក្រៅពីនេះ របាយការណ៍បានបង្ហាញថែមទៀតថា ៩០ ភាគរយ នៃស្ត្រីទាំងនោះរងគ្រោះយ៉ាងធ្ងន់ធ្ងរដែលចាំបាច់ទាមទារការថែទាំសុខភាព ប៉ុន្តែជាក់ស្តែងមានតែ ៥៣ ភាគរយ ប៉ុណ្ណោះក្នុងចំណោម ៩០ ភាគរយដែលបានទទួលបានការព្យាបាល។ យោងតាមរបាយការណ៍មួយក្នុងឆ្នាំ២០១៧ ធ្វើឡើងដោយអង្គការយូនីសេហ្វបានបង្ហាញថាកុមារជាង ២០ភាគរយមានអាយុក្រោម៤ឆ្នាំបានកំពុងរស់នៅជាមួយម្តាយដែលជាជនរងគ្រោះដោយអំពើហិង្សាលើផ្លូវកាយ ផ្លូវភេទ និងផ្លូវអារម្មណ៍ដោយប្តី ឬដៃគូរបស់ពួកគាត់ក្នុងរយៈ ១២ខែចុងក្រោយនេះនៅក្នុងប្រទេសកម្ពុជា។

ជាក់ស្តែង អ្នកប្តូរយេនឌ័រជាស្ត្រីគឺជាជនងាយទទួលរងពីអំពើហិង្សាផ្អែកលើយេនឌ័រផងដែរ។ របាយការណ៍ដែលចេញផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅឆ្នាំ២០១៦ បានបង្ហាញពីអត្រាគួរឱ្យព្រួយបារម្ភនៃការរំលោភសិទ្ធិប្រឆាំងនឹងអ្នកប្តូរភេទជាស្ត្រីទៅតាមទីសាធារណៈ ក្នុងនោះ ៤៣ ភាគរយ នៃអ្នកផ្តល់បទសម្ភាសន៍គឺជាជនរងគ្រោះនៃអំពើហិង្សាលើរូបរាយកាយ ៣១ភាគរយគឺជាជនរងគ្រោះនៃការបំពានផ្លូវភេទ និង២៥ ភាគរយ គឺជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈ។

អ្នករកស៊ីផ្លូវភេទក៏ប្រឈមយ៉ាងធ្ងន់ធ្ងរដោយទទួលរងការរើសអើង និងការយាយីពីសំណាក់អតិថិជនជាបុរស និងមន្ត្រីអនុវត្តច្បាប់ផងដែរ។ បញ្ហានេះអាចឆ្លុះបញ្ចាំងតាមរយៈករណីអ្នករកស៊ីផ្លូវភេទម្នាក់ឈ្មោះប៉ែន គន្ធា កាលពីឆ្នាំ២០១៧ ដែលបានលង់ទឹកស្លាប់នៅទន្លេសាបក្រោយពីសន្តិសុខមួយក្រុមក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ បានដេញតាមចាប់នាង។ សាក្សីនៅកន្លែងកើតហេតុបានរាយការណ៍ថា សន្តិសុខបានហាមឃាត់អ្នកនៅកន្លែងកើតហេតុនោះមិនឲ្យជួយស្ត្រីលង់ទឹកនោះទេ ហើយក៏មិនមានការស៊ើបអង្កេតណាមួយបានចាប់ផ្តើមឡើយ។

ការជួញដូរមនុស្សជាទម្រង់មួយនៃអំពើហិង្សាដែលផ្អែកលើយេនឌ័រ ហើយក៏ជាបញ្ហាមួយដែលប៉ះពាល់យ៉ាងខ្ពស់ទៅលើស្ត្រីកម្ពុជាជាច្រើន។ អំពើខុសច្បាប់ និងការជួញដូរមនុស្សឆ្លងព្រំដែនបង្កជាបញ្ហាផ្សេងៗ សម្រាប់ស្ថាប័ននានាដែលមានភារកិច្ចប្រយុទ្ធប្រឆាំងនឹងបញ្ហាទាំងនោះត្រូវស្វះស្វែងរកជនល្មើសនិងបញ្ជូនជនល្មើសដើម្បីផ្តន្ទាទោសតាមច្បាប់។ ជាក់ស្តែងការស្រាវជ្រាវដែលបានផ្តល់ឡើងដោយរដ្ឋាភិបាលអាមេរិកក្នុងឆ្នាំ២០១៧ បានចេញផ្សាយថា ការអនុវត្តច្បាប់

របស់អាជ្ញាធរនៅក្នុងប្រទេសកម្ពុជាបានទទួលផលប្រយោជន៍ពីជនដែលសង្ស័យថាជួញដូរមនុស្សនិងជួញដូរផ្លូវភេទ និងរក្សាទុករឿងក្តីមិនចាត់ការចំពោះជនល្មើសណាដែលពាក់ព័ន្ធរឿងនិយោបាយបទឧក្រិដ្ឋ និងចំណងសេដ្ឋកិច្ចជាមួយមន្ត្រីរបស់រដ្ឋាភិបាល។

ក្នុងប្រទេសកម្ពុជាអំពើហិង្សាផ្អែកលើយេនឌ័របានកើតឡើងទៅបានក៏ដោយសារតាមរយៈប្រព័ន្ធយុត្តិធម៌ដែលត្រូវបានរិះគន់អំពីភាពអប្រសិទ្ធភាព ភាពព្រងើយកន្តើយ និងការកើតមានអំពើពុករលួយផងដែរ។ មានតំណាងតិចតួចជាស្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌ដែលជាក់ស្តែងចៅក្រមជាស្ត្រីមានចំនួនតែ ១៤ ភាគរយនៅទូទាំងប្រទេស និងមេធាវីជាស្ត្រីចំនួនតែ ២០ភាគរយ ប៉ុណ្ណោះ។ របាយការណ៍ពាក់ព័ន្ធនឹងភាព មិនអំណោយផលដល់យេនឌ័រក្នុងប្រព័ន្ធយុត្តិធម៌នោះគឺថាស្ត្រីដែលជាជនរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយេនឌ័រ ជាញឹកញយ ត្រូវបានគេស្តីបន្ទោស សើចចំអក ឬបាក់ស្បាតលើសបន្ថែមទៀត ដោយសារអ្នកធ្វើការនៅក្នុងវិស័យយុត្តិធម៌។




បញ្ហាទាំងនេះ រួមជាមួយជំនឿវប្បធម៌ ដែលថាបញ្ហាគ្រួសារគឺជាបញ្ហាផ្ទាល់ខ្លួន នាំឱ្យស្ត្រីជាច្រើនបានឆ្លងកាត់អំពើហិង្សាផ្អែកលើយេនឌ័រ ហើយពួកគាត់មិនមានឱកាសទទួលបានយុត្តិធម៌។ ក្នុងសំណុំរឿងអំពើហិង្សាក្នុងគ្រួសារ ជាធម្មតាស្ត្រីត្រូវបានលើកទឹកចិត្តឲ្យស្វែងរកដំណោះស្រាយតាមវិធីផ្សះផ្សាក្រៅផ្លូវការដែលផ្ទុយនឹងនីតិវិធីច្បាប់។ ថ្វីបើតាមក្របខណ្ឌច្បាប់ ការប្រើប្រាស់មធ្យោបាយផ្សះផ្សាគឺជាវិធីមួយដែលឆ្លើយតបទៅនឹងអំពើហិង្សាក្នុងគ្រួសារ ដោយតម្រូវឲ្យភាគីទាំងពីរមានការព្រមព្រៀងគ្នាយ៉ាងណាក្តី ចំណោទត្រង់ថាក្នុងករណីបែបនោះតើស្ត្រីមានលទ្ធភាពក្នុងការសម្រេចចិត្តដោយគ្មានការបង្ខំដែរឬយ៉ាងណា ជាពិសេស ការដែលត្រូវបានរងការឈឺចាប់ផ្នែកផ្លូវចិត្តដោយសាររងគ្រោះអំពើហិង្សាញឹកញាប់ពេក។ ជាការកត់សម្គាល់ ការស្រាវជ្រាវដែលធ្វើឡើងដោយអង្គការសហប្រជាជាតិបានបង្ហាញថា ៩៨,៥ ភាគរយ នៃស្ត្រីកម្ពុជាជឿថាពួកគាត់ត្រូវតែគោរពស្តាប់តាមប្តីរបស់គាត់។

## ការការពារដោយច្បាប់ជាតិ

ច្បាប់ជាតិរបស់កម្ពុជាហាមឃាត់អំពើហិង្សាផ្អែកលើយេនឌ័ ហើយការពារសិទ្ធិស្មើគ្នានិងប្រឆាំងនឹងការរើសអើងនិងការរំលោភបំពានដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (“រដ្ឋធម្មនុញ្ញ”) ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (“ក្រមព្រហ្មទណ្ឌ”) និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ (“ច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ”) ។

រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិនិងសេរីភាពស្មើគ្នាដល់ប្រជាពលរដ្ឋខ្មែរទាំងអស់រួចផុតពីការរើសអើងដោយមិនគិតពីភេទដូចមានចែងក្នុងមាត្រា៣១ និង៤២។ ទន្ទឹមគ្នានេះដែរ ក្រមព្រហ្មទណ្ឌហាមឃាត់ចំពោះរូបភាពនៃអំពើហិង្សាជាច្រើនដែលប៉ះពាល់ដល់ស្ត្រីដូចជាការរំលោភ (មាត្រា ២៣៩) ការយាយីផ្លូវភេទ (មាត្រា ២៥០) និងពេស្យាចារ (មាត្រា ២៨៥) ។ ថ្វីបើបទប្បញ្ញត្តិទាំងនេះចែងអំពីជំហានវិជ្ជមានដ៏ជាក់លាក់ក្នុងការសម្រេចបាននូវការធានាសេរីភាពរបស់ស្ត្រីពីអំពើហិង្សា ប៉ុន្តែច្បាប់ទាំងនោះគឺនៅតែមិនទាន់គ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញ និងភាពប្លែកៗពីគ្នានៃអំពើហិង្សាប្រឆាំងនឹងយេនឌ័រដែលកើតឡើងនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។

ច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារបានអនុម័តនៅឆ្នាំ២០០៥ ច្បាប់នោះបានចែងបន្ថែមដើម្បីហាមឃាត់នូវរាល់ទម្រង់នៃអំពើហិង្សាដែលត្រូវបានកើតមាននៅក្នុងប្រទេសកម្ពុជា។ ជាពិសេស ច្បាប់បានកំណត់ទោសព្រហ្មទណ្ឌទៅលើ

ការរំលោភបំពានផ្លូវកាយនិងផ្លូវចិត្តដែលប្រឆាំងនឹងសមាជិកគ្រួសារណាម្នាក់ (មាត្រា៥ និងមាត្រា៦) ដូចជារាល់ទម្រង់នៃការបៀតបៀនផ្លូវភេទ រួមទាំង ការឃាយី និងហិង្សាលើផ្លូវភេទជាដើម (មាត្រា ៧) ។ តែទោះបីជាយ៉ាងណា ច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារនៅតែចែងមិនគ្រប់ជ្រុងជ្រោយដើម្បីផ្តល់ការការពារឲ្យបានទូលំទូលាយជាចាំបាច់ក្នុងបរិបទនៃអំពើហិង្សាក្នុងគ្រួសារ។ ឧទាហរណ៍ និយមន័យដែលមាននៅក្នុងច្បាប់ ថាតើអំពើណាខ្លះចាត់ទុកជាអំពើហិង្សាក្នុងគ្រួសារនិងអ្នកណាដែលអាចជាជនរងគ្រោះ មិនមានចែងច្បាស់លាស់នូវរូបភាពជាច្រើននៃការរំលោភបំពានក្នុងគ្រួសារទេ ។

## ការការពារដោយច្បាប់អន្តរជាតិ

អនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ សន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់ដែលកម្ពុជាជារដ្ឋសមាជិក ត្រូវតែបានបញ្ចូលក្នុងច្បាប់ជាតិដោយស្វ័យប្រវត្តិ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាមួយចំនួនដែលពាក់ព័ន្ធនឹងការលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ។ ជាដំបូងគេបង្អស់នោះ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ សង្គមកិច្ចសេដ្ឋកិច្ចនិងវប្បធម៌ឆ្នាំ១៩៦៦ បានបញ្ជាក់ពីភាពស្មើគ្នារបស់ស្ត្រី និងសិទ្ធិសេរីភាពរួចផុតពីការរើសអើង (មាត្រា ២)។ បន្ទាប់មក កម្ពុជាក៏បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី("ស៊ីដ") ។ ស៊ីដ មានលក្ខណៈលម្អិតក្នុងការហាមឃាត់ការរើសអើងប្រឆាំងនឹងស្ត្រីទាំងក្នុងជីវភាពពលរដ្ឋ នយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ ។ ជាពិសេស ស៊ីដបានផ្តល់នូវអនុសាសន៍ទូទៅចំនួន២ (លេខ១៩ និងបច្ចុប្បន្នភាពលេខ៣៥) ដើម្បីលើកឡើងជាក់ស្តែងអំពីអំពើហិង្សាផ្អែកលើយេនឌ័រដែលមានលក្ខណៈទូលំទូលាយ និងផ្តល់នូវនិយមន័យអំពើហិង្សាច្បាស់លាស់ និងបញ្ជាក់ច្បាស់លាស់អំពីការអនុវត្តន៍អនុសញ្ញាក្នុងបរិបទទាំងនោះ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ថ្វីបើច្បាប់ជាតិនិងអន្តរជាតិមានចែងច្បាស់លាស់ក្នុងការកំណត់នូវកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងការលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រក៏ដោយ ក៏នៅមានកាតព្វកិច្ចជាច្រើនទៀតដែលត្រូវតែពង្រឹង។ ដូចនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សូមលើកឡើងនូវអនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តតាមវិធានការអប្បបរមាដូចខាងក្រោមដើម្បីការពារសិទ្ធិស្ត្រីនៅកម្ពុជានៅត្រឹមឆ្នាំ២០២១ ដែលជាការផុតកំណត់នៃការដាក់របាយការណ៍បន្ទាប់របស់កម្ពុជាជូនចំពោះគណៈកម្មាធិការស៊ីដស្តីពីសកម្មភាពដែលត្រូវបានអនុវត្តដើម្បីលើកកម្ពស់ការយល់ដឹងនូវសិទ្ធិដែលបានចែងនៅក្នុងអនុសញ្ញានេះ។

- ***វិសោធនកម្មច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងក្រមព្រហ្មទណ្ឌ*** *ដើម្បីដោះស្រាយឲ្យបានទូលំទូលាយនូវរាល់រូបភាពនៃអំពើហិង្សាផ្អែកលើយេនឌ័រដែលស្ត្រីកម្ពុជាបានជួបប្រទះ ។*
- ***ខិតខំប្រឹងប្រែងតាមដានសកម្មភាពដែលជាអំពើហិង្សានិងការរើសអើង****ប្រឆាំងនឹងស្ត្រីដែលមានដាក់ក្នុងផែនការនារីរតនៈទី ៤ ដោយផ្សព្វផ្សាយព័ត៌មានជាសាធារណៈលើបញ្ហាដែលកើតមានជារឿយៗនិងផលប៉ះពាល់អវិជ្ជមាន។*
- ***ផ្តល់ធនធានឲ្យបានគ្រប់គ្រាន់ទៅមន្ត្រីនគរបាល*** *ដើម្បីធានាថាករណីរំលោភទាំងអស់ត្រូវបានស៊ើបអង្កេតយ៉ាងត្រឹមត្រូវ និងសមស្រប បន្ថែមលើកិច្ចប្រឹងប្រែងដែលមានស្រាប់របស់ក្រសួងកិច្ចការនារីក្នុងការបណ្តុះបណ្តាលមន្ត្រីនគរបាលដូចដែលបានលើកឡើងនៅក្នុងនារីរតនៈទី៤ ។*
- ***ចាត់វិធានការឲ្យមានប្រសិទ្ធិភាពដើម្បីលុបបំបាត់ការរើសអើងទៅលើស្ត្រីនៅស្ថាប័នយុត្តិធម៌*** *ឧទាហរណ៍ដូចជាការផ្តល់វគ្គបណ្តុះបណ្តាលឲ្យបានទូលាយនៅក្នុងវិស័យតុលាការ និងមន្ត្រីអនុវត្តច្បាប់អំពីបញ្ហាជាក់លាក់របស់ស្ត្រីរួមមាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ*

- ***ចាត់វិធានការនានាដើម្បីប្រឆាំងនឹងនិទណ្ឌភាពចំពោះអំពើហិង្សាប្រឆាំងនឹងស្ត្រី*** *ដោយរាប់ទាំងវិធានការដើម្បីស៊ើបអង្កេតដោយឯករាជ្យ កាត់ទោសនិងការដាក់ទោសអំពើហឹង្សាដែលប្រព្រឹត្តដោយភ្នាក់ងាររដ្ឋ។*

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកញ្ញា មុំ សុផាន្នី អ្នកសម្របសម្រួលគម្រោងលេខទូរសព្ទ +៨៥៥ (០)១១ ៣១០ ៧៧៨ ឬតាមរយៈអ៊ីមែល sophanny.mom@cchrcambodia.org.

**---ចប់---**